ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

SOCIAL PROTECTION IN CAMBODIA

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី១៩)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ១៨ ៨១៤ នាក់ នៃរោងចក្រ សហគ្រាស ទាំង៦២ នៃវិស័យកាត់ដេរ និងវិស័យទេសចរណ៍ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីជុំទី៣នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាលជ្រាបថា ធនាគារឯកទេសវីង នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរស័ព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួន៖

- ៦០ ៧៥០រៀល (១៥ដុល្លារអាមេរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១០ថ្ងៃ
- ១២១ ៥០០រៀល (៣០ដុល្លារអាមេរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ១៦២ ០០០រៀល (៤០ដុល្លារអាមេរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ១ខែ។ សូមបញ្ជាក់ថា សម្រាប់បងប្អូនដែលព្យួរកិច្ចសន្យាការងាររយៈពេល ២ខែ ប្រាក់ឧបត្ថម្ភនឹងត្រូវបើកជា ២លើក ដោយលើកទី២ នឹងបើកនៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០២០។

ក្រសួងសូមរំឭកថា ធនាគារឯកទេសវីង នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខានមិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរស័ព្ទពីធនាគារឯកទេសវីង។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរស័ព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាស ទាំង៦២ នេះ មិនបានទទួលសារទូរស័ព្ទពីធនាគារឯកទេសវីង នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរស័ព្ទរបស់ខ្លួន ទៅរដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មកររោងចក្រ សហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃ ពុធ ៩កើត ខែ ស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល

ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២០

បញ្ជីឈ្មោះ រោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍
ចំនួន ៦២ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| ក. វិស័យកាត់ដេរ | | 32 |
| 1 | ក្រុមហ៊ុនឌូហ៊ីស្ត(ខេមបូឌា) | ភ្នំពេញ |
| 2 | ក្រុមហ៊ុនអេសអ៊ីភីអាយអេ (ខេមបូឌា) ហ្គាមេន | ភ្នំពេញ |
| 3 | ក្រុមហ៊ុនវ៉ុដុងអ៊ីនដាសស្ទ្រៀល | ភ្នំពេញ |
| 4 | ក្រុមហ៊ុនវីនខេម ខបភើរេសិន | ភ្នំពេញ |
| 5 | ក្រុមហ៊ុនស៊ីកូ(ភ្នំពេញ)ខូអិលធីឌី | ភ្នំពេញ |
| 6 | ក្រុមហ៊ុនកូកូវ៉ុល អឺភែរឹល (ខេមបូឌា) អ៊ីន | ភ្នំពេញ |
| 7 | ក្រុមហ៊ុនភើហ្វិក ស៊ីមឡេស ហ្គាម៉ិន (ខេមបូឌា) លីមីធីត | ភ្នំពេញ |
| 8 | ក្រុមហ៊ុនកូកូវ៉ុល អឺភែរឹល (ខេមបូឌា) អ៊ីន (ការិយាល័យកណ្តាល) | ភ្នំពេញ |
| 9 | ក្រុមហ៊ុនសាប ភ្នំពេញ ឯ.ក | ភ្នំពេញ |
| 10 | ក្រុមហ៊ុនអេស.វ៉ាយ អ៊ីមប្រយឌើរី ឯ.ក | ភ្នំពេញ |
| 11 | ក្រុមហ៊ុនជេអេស លេឌើរ ខលលិកសិន ភ្នំពេញ ឯ.ក សាខាទី២ | ភ្នំពេញ |
| 12 | ក្រុមហ៊ុនលូសេន ថេកស្តាយ(ខេមបូឌា) | ភ្នំពេញ |
| 13 | ក្រុមហ៊ុនឥណ្ឌូចិនអឺភែរឹល (ខេមបូឌា) អិលធីឌី | កណ្តាល |
| 14 | ក្រុមហ៊ុនណាហ្គាភីសខបភើរេសិនលីមិតធីត | កណ្តាល |
| 15 | ក្រុមហ៊ុនបូវយើរ ហ្គាមេនហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីតធីត | កណ្តាល |
| 16 | ក្រុមហ៊ុនជីនវីន អ៊ីនដាសស្ទ្រី ខេមបូឌា ខូអិលធីឌី | កណ្តាល |
| 17 | ក្រុមហ៊ុនស៊ីអិនឌីហ្គ្រី អិនធើណេសិនណល (ខេអេច) ឯ.ក | កំពង់ស្ពឺ |
| 18 | ក្រុមហ៊ុនចិចសាន់(ខេមបូឌា)នីតធីង វ៉ុស៊ីង ដាយអ៊ីង អេន ព្រីនធីង ឯ.ក | កំពង់ស្ពឺ |
| 19 | ក្រុមហ៊ុនយូនៀន លេឌើវែរ អឹម.អេហ្វ.វ៉ាយ ឯ.ក | កំពង់ស្ពឺ |

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 20 | ក្រុមហ៊ុនសាប្រ៊ីណា (ខេមបូឌា) ហ្គាម៉ិន ម៉ែនញ៉ូហ្វាក់ឆឺរីន ខប | កំពង់ស្ពឺ |
| 21 | ក្រុមហ៊ុនម៉ាស្ទ័រ-យីង ហ្គាម៉ិន មេនូហ្វេកឆឺរីង (ខេមបូឌា) ឯ.ក | កំពង់ស្ពឺ |
| 22 | ក្រុមហ៊ុនទ្រីនីធី ហៃនប៉ែក ខូអិលធីឌី | កំពង់ស្ពឺ |
| 23 | ក្រុមហ៊ុនអេសអិម ស៊ូ មេធៀរៀល(SM) (បោះពុម្ព) ឯ.ក | កំពង់ស្ពឺ |
| 24 | ក្រុមហ៊ុនហុងគុងវីនហ្វៃរហ្គាមេន(ខេមបូឌា)អិលធីឌី | កំពង់ស្ពឺ |
| 25 | ក្រុមហ៊ុនណានវ៉ាង ត្រាវែល ហ្គូដស៍ ឯក | កំពង់ស្ពឺ |
| 26 | ក្រុមហ៊ុនអៅដរ ហ្គៀ (ខេមបូឌា) ឯ.ក | តាកែវ |
| 27 | ក្រុមហ៊ុនណាញ ស្គាយ ហ្គាម៉ិន ឯ.ក | តាកែវ |
| 28 | ក្រុមហ៊ុនលីនតុន មេនូហ្វេកឆឺរីង ឯ.ក | តាកែវ |
| 29 | ក្រុមហ៊ុនហ៊ីវ៉ាយហ្សិន អៅដរ(ខេមបូឌា)ខូ,.អិលធីឌី | កំពង់ឆ្នាំង |
| 30 | ក្រុមហ៊ុនខេន ស្គ័ត ស៊ូ | កំពង់ឆ្នាំង |
| 31 | ក្រុមហ៊ុនស៊ីកូ (ខេមបូឌា) ខូអិលធីឌី | ស្វាយរៀង |
| 32 | ក្រុមហ៊ុនអ៊ីលីត (ខេមបូឌា) ខូអិលធីឌី | ស្វាយរៀង |
| ខ. វិស័យទេសចរណ៍ | | 30 |
| 33 | សណ្ឋាគារ ហ្គាឌិន ស៊ីធី ហូថេល | ភ្នំពេញ |
| 34 | ក្រុមហ៊ុនផូគីថា រីសត & ស្ប៉ា (ខេមបូឌា) | ភ្នំពេញ |
| 35 | សណ្ឋាគាររ៉ាហ្វិលរ៉ូយ៉ាល់ | ភ្នំពេញ |
| 36 | ក្រុមហ៊ុនផ្លេនថេសិន ហូថេល | ភ្នំពេញ |
| 37 | ក្រុមហ៊ុន ឥណ្ឌូឆាយណា ស៊ើវីសស៍ (ខេមបូឌា) លីមីតធីត | ភ្នំពេញ |
| 38 | ក្រុមហ៊ុនអាយវ៉ុន ធេហ្វ អេហ្វ&ប៊ី (ខេមបូឌា)ឯ.ក | ភ្នំពេញ |
| 39 | ក្រុមហ៊ុនអេស៊ា អិចផ្លរើ ត្រាវែល | ភ្នំពេញ |
| 40 | ក្រុមហ៊ុនតាយម៉េង ប្លាហ្សា អូតែល | ភ្នំពេញ |
| 41 | ក្រុមហ៊ុនកាំបូឌីយ៉ាណា អ៊ិនវេស្តមេនធ៍ (ភ្នំពេញ) ភីធីអ៊ី អែលធីឌី | ភ្នំពេញ |
| 42 | ក្រុមហ៊ុនភី.ធី.អិម (ត្រាវែល & ធួរ) | ភ្នំពេញ |
| 43 | ក្រុមហ៊ុនឌីថាមត្រាវែល ខេមបូឌា | ភ្នំពេញ |
| 44 | ក្រុមហ៊ុនឆេនណល សាយថ៍ ឌីស្ទ្រីប៊ូសិន | ភ្នំពេញ |
| 45 | ក្រុមហ៊ុនអេមខេត (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 46 | ក្រុមហ៊ុនហូខឹស អេស៊ា អ៊ីនធើណេសិនណលត្រាវែល ស៊ើវីស | សៀមរាប |
| 47 | សណ្ឋាគារសោមាទេវីអង្គររីសត & ស្ប៉ា | សៀមរាប |
| 48 | ក្រុមហ៊ុនជាតិថាតា អង្គរ | សៀមរាប |

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 49 | សណ្ឋាគារប៉ាស៊ីហ្វិក | សៀមរាប |
| 50 | សណ្ឋាគារប៉ារ៉ាឌីសអង្គរវីឡា | សៀមរាប |
| 51 | ក្រុមហ៊ុនរុក្ខៈ រីវើរ រីសត | សៀមរាប |
| 52 | សណ្ឋាគារ សិន្ធា មុន្នី | សៀមរាប |
| 53 | ក្រុមហ៊ុនដំរីអង្គរ ខូ អិលធីឌី | សៀមរាប |
| 54 | សណ្ឋាគារ អង្គរប៉ារ៉ាឌី | សៀមរាប |
| 55 | ក្រុមហ៊ុនស៊ីវ៉ាយ-អេសអ ហូថេល ហ្វ្រេន ឡាយអិន ឯ.ក | សៀមរាប |
| 56 | ក្រុមហ៊ុនខ្មែរអង្គរហូថែលកូអិលធីឌី | សៀមរាប |
| 57 | ក្រុមហ៊ុនអង្គររ៉ែលេសរីហ្សត និងស្ប៉ា | សៀមរាប |
| 58 | ក្រុមហ៊ុនអេប៉ិច ខេមបូឌា ត្រាវែល ស៊ែរវីស | សៀមរាប |
| 59 | ក្រុមហ៊ុនអ៊ីបេន ទ្រី ហាត់ | សៀមរាប |
| 60 | ភោជនីយដ្ឋាន នារីខ្មែរ | សៀមរាប |
| 61 | ភោជនីយដ្ឋាន ហាទៀន វីហ្គាស | កំពត |
| 62 | ក្រុមហ៊ុនថ្មរូង ឌីវេឡុបមេន | ព្រះសីហនុ |